ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមហ៊ុនហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល**
**(ខេមបូឌា) ភីអិលស៊ី**

*ថ្ងៃពុធ ៦ កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤*
*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១*

# សេចក្តីប្រកាសព័ត៌មាន

ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី (ក្រុមហ៊ុន"ហ្គ្រេនធ្វីន") មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ ភាគហ៊ុនិក វិនិយោគិន និងសាធារណជន ទាំងអស់មេត្តាជ្រាបថា ៖ ក្រុមហ៊ុនបានបង្ហាញព័ត៌មាននៅលើគេហទំព័ររបស់ផ្សារមូលបត្រកម្ពុជា នៅពីថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០២១ អំពីការថយចុះនៃប្រាក់ចំណូល និង មានភ្ជាប់នូវព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ក្នុងត្រីមាសទី៤ ឆ្នាំ២០២០ (ជាភាសាខ្មែរ) ដែលមានកំហុសឆ្គងផ្នែក បច្ចេកទេសលើតួលេខនៃការបម្រែបម្រួលចំណូលថយចុះចំនួន **៥៩.២០៦.៣៨៧ ពាន់រៀល** និងតួលេខថ្លៃដើម កំណត់សម្គាល់លេខ១៨ ចំនួន **៤៥៤.៩៤៤.៧៤៣ពាន់រៀល** ក្នុងរបាយការណ៍ចំណូល ឬខាត និងលទ្ធផលពេញលេញសង្ខេបបណ្តោះអាសន្នសម្រាប់១២ខែ នៃព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ក្នុងត្រីមាសទី៤ ឆ្នាំ២០២០ ។

ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី សុំធ្វើការកែតម្រូវតួលេខដែលត្រឹមត្រូវ គឺបម្រែបម្រួលចំណូលថយចុះចំនួន **(៥៩.២០៦.៣៨៧ពាន់រៀល)** និង ថ្លៃដើមចំនួន **៤៥៥.៩៤៤.៧៤៣ពាន់រៀល** ។

ក្រុមហ៊ុន សូមជម្រាបថា ការកែតម្រូវតួលេខនេះ មិនមានប៉ះពាល់ដល់ ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ក្នុងត្រីមាសទី៤ ឆ្នាំ២០២០ ទាំងមូលទេ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិក វិនិយោគិន និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

*សូមភ្ជាប់ជូនមកជាមួយនូវព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ក្នុងត្រីមាសទី៤ ឆ្នាំ២០២០ (ភាសាខ្មែរ)។*

**ក្រុមហ៊ុនហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី**

ទីស្នាក់ការ: ភូមិត្រពាំងពោធិ៍សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ:២៣ ៨៩០ ៣២៥(៨៥៥) /ទូរសារ :២៣ ៨៩០ ៣២៦(៨៥៥) / គេហទំព័រ : www.Grandtwins.com.kh/អ៊ីម៉ែល : vuthy.phuong@qmico.com